

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ  សាសនា ព្រះមហាក្សត្រ

# បទបង្ហាញ

# ស្តីពី

# ការហ្វឹកហ្វឺនកូនជាង

បង្ហាញដោយលោក នេន  ទុទ្ធី

អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦

# មាតិកា

១- គោលបំណង

២-លទ្ធផលរំពឹងទុក

៣-លក្ខណៈច្បាប់

៤-ភាពងាយស្រួល

៥-លទ្ធផលការងារ

៦-បញ្ហាប្រឈម

៧-អនុសាសន៍

# គោលបំណង

- បង្កើនធនធានមនុស្សឲ្យមានជំនាញសម្រាប់បម្រើការងារតាមសង្វាក់ផលិតកម្ម សេវាកម្ម នៅក្នុងសហគ្រាស គ្រឹះស្ថានផ្ទាល់។

- បង្កឲ្យមានភាពទំនាក់ទំនងវិជ្ជាជីវៈល្អ រវាងនិយោជក និងកម្មករនិយោជិត ដើម្បីបង្កើនភាពសុខដុមនីយកម្មជាមួយគ្នា។

# លទ្ធផលរំពឹងទុក

**និយោជក មនុស្ស** : **ទទួលបានធនធាន ដែលមានជំនាញ ដើម្បីបង្កើនផលិតភាពខ្ពស់។**

**កម្មករនិយោជិត** : ទទួលបានជំនាញ អាចបម្រើការងារតាមការបញ្ជាទិញ ពិសេសទទួលបានប្រាក់បៀវត្សខ្ពស់។

# លក្ខណៈច្បាប់

**កូនជាង** គឺជាជនដែលបានចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជក ឬសិប្បករណាម្នាក់ដែលបានចុះកិច្ចសន្យានឹងគ្នាថា និយោជកត្រូវបង្រៀន ឬប្រើឲ្យគេបង្រៀនវិជ្ជាជីវៈខ្លួនហើយកូនជាងត្រូវធ្វើការឲ្យនិយោជកតែតាមលក្ខខណ្ឌនិងក្នុងរយៈពេលនៃកិច្ចសន្យា។

- ការហ្វឹកហ្វឺនកូនជាងមានកំណត់នៅក្នុងច្បាប់ស្តីពីការងារនៅជំពូកទី៣
- វាជាកាតព្វកិច្ចរបស់និយោជក ដែលមានប្រើប្រាស់កម្មករនិយោជិតច្រើនជាងហុកសិប(៦០)នាក់ត្រូវមានកូនជាងស្មើនឹងមួយភាគដប់ ១០% នៃចំនួនកម្មករនិយោជិតដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថាននោះ។
- ក្នុងករណីសហគ្រាសណាមិនបានរៀបចំការហ្វឹកហ្វឺនកូនជាង តម្រូវឲ្យបង់ពន្ធអាករជំនួសវិញ។ ពន្ធអាករត្រូវបង់តាមអត្រាកំណត់មួយភាគរយ (១%) លើប្រាក់ឈ្នួលប្រចាំឆ្នាំនៃចំនួនសរុបកម្មករនិយោជិតទាំងអស់របស់សហគ្រាសជារៀងរាល់ឆ្នាំ។

# ភាពងាយស្រួល

- ការហ្រ៊ីកហ្វ៊ីនកូនដាំងអនុវត្តទៅបានដោយសារមានច្បាប់ស្តីពីការងារ បទបញ្ជា បទបញ្ញត្តិ ព្រមទាំងមានប្រកាសស្តេចក្តីណែនាំសម្រាប់បកស្រាយទៅលើខ្លឹមសារនៃច្បាប់ដើម្បីងាយស្រួលក្នុងការអនុវត្ត។ ប្រកាសជានីតិវិធីក្នុងការអនុវត្តឲ្យបានស្របច្បាប់ ដោយមានការពន្យល់លើមាត្រានៃច្បាប់ដែលពាក់ព័ន្ធទៅលើការអនុវត្តជាក់ស្តែងរបស់សហគ្រាស គ្រឹះស្ថាន។

- មានមន្ត្រីទទួលខុសត្រូវលើជំនាញការហ្វឹកហ្វឺនកូនដាំងដោយបានបណ្តុះបណ្តាល បំប៉នជំនាញបន្ថែម ដើម្បីបង្កើនសមត្ថភាព គុណភាពដល់មន្ត្រីដែលចូលថ្មី និងមន្ត្រីដែលកំពុងបម្រើការសព្វថ្ងៃជាប្រចាំតាមរយៈការបំប៉នបច្ចេកទេស ច្បាប់ នៅតាមបណ្តារាជធានី-ខេត្ត និងមានការធ្វើសិក្ខាសាលាប្រចាំឆ្នាំ ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ការងារដាក់ស្តែងជារៀងរាល់បំណាច់ឆ្នាំ។

# លទ្ធផលការងារ

- តាមរយៈការហ្វឹកហ្វឺនកូនជាងបានចំនួន ២៥០-២៨០ សហគ្រាស ដែលមានកូនជាងចំនួនពី ១0000 នាក់-១៥000 នាក់ ជារៀងរាល់ឆ្នាំ លើគ្រប់វិស័យដូចជា កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម គមនាគមន៍ សំណង់ សេវាកម្ម ហើយចំនួនដែលលេចធ្លោជាងគេ ផ្នែកកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង។

# បញ្ហាប្រឈម

- ខ្វះមន្ត្រីជំនាញសម្រាប់ការចុះធ្វើអធិការកិច្ចការងារ
- ខ្វះមធ្យោបាយ ប្រាក់ឧបត្ថម្ភដល់មន្ត្រីក្នុងការចុះធ្វើអធិការកិច្ចការងារ
- សហគ្រាស គ្រឹះស្ថានមួយចំនួននៅខ្វះការសហការដោយលាក់ចំនួនកម្មករនិយោជិត
- ការអនុវត្តច្បាប់ស្តីពីការងា នៅពុំទាន់មានប្រសិទ្ធភាពដោយសហគ្រាស គ្រឹះស្ថានមួយចំនួនពុំព្រមអនុវត្ត

- សហគ្រាស គ្រឹះស្ថាន មួយចំនួនមិនបានចុះបញ្ជីប្រកបអាជីវកម្មឲ្យបានត្រឹមត្រូវតាមលក្ខណៈច្បាប់ (Subcontract) ងាយបិទ ទៅបើកកន្លែងថ្មី

- សហគ្រាស គ្រឹះស្ថាន ការផ្លាស់ប្តូរអ្នកគ្រប់គ្រងញឹកញាប់ (រដ្ឋបាល HR)

# អនុសាសន៍

- ពង្រីកការផ្សព្វផ្សាយច្បាប់ស្តីពីការងារឲ្យបានទូលំទូលាយដល់សាធារណៈជន ពិសេសនិយោជក អ្នកវិនិយោគ ដើម្បីបានយល់ឲ្យកាន់តែច្បាស់អំពីច្បាប់
- និយោជក ត្រូវតែគោរពច្បាប់ស្តីពីការងារឲ្យបានត្រឹមត្រូវ និងប្រកាសនានាដែលពាក់ព័ន្ធ
- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) គួរជួយជំរុញដល់សមាជិករបស់ខ្លួនឲ្យអនុវត្តកាតព្វកិច្ចហ៊ឹកហ្វឺនកូនជាងប្រចាំឆ្នាំ។

- និយោជក វិស័យឯកជន គួរតែចូលរួមក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឲ្យធនធានមនុស្សបានច្រើន និងមានជំនាញពិតប្រាកដ តាមទាន់បច្ចេកវិទ្យាដែលមានការវិវត្តន៍រីកចម្រើនជារៀងរាល់ថ្ងៃ (វិក្រឹតការជំនាញ)

- ត្រូវធ្វើការបណ្តុះបណ្តាល និងបំប៉នសមត្ថភាពដល់មន្ត្រីដែលអនុវត្តផ្ទាល់ជាប្រចាំ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ កុំឲ្យមានការប្រាសចាកពីកន្លងច្បាប់។


សូមអរគុណ
ចំពោះលោក-លោកស្រីក្នុងការយកចិត្ត
ទុកដាក់ស្តាប់